# ពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា

THE MINNESOTA CAMBODIAN BUDDHIST SOCIETY; INC.
A NON-PROFIT RELIGIOUS INCORPORATION
2925 220th Street East, Hampton, MN 55031 Tel: (651) 463-3101 Fax: (651) 460-4464
www.wattmunisota.org


# បុណ្យចូលឆ្នាំថ្មី

បុណ្យចូលឆ្នាំថ្មី គឺជាបុណ្យប្រពៃណីខ្មែរដែលមានតាំងពីបូរាណកាលមក បុណ្យនេះ ខេមរជនរមែងធ្វើឡើង ដោយមានគោលបំណងសំខាន់ៗ ដូចតទៅ ៖

-ដើម្បីថែរក្សាទុកនូវប្រពៃណីដ៏ល្អរបស់ជាតិខ្មែរយើង ឱ្យបានគង់វង់ស្ថិតស្ថេររស់កាលជាយូរអង្វែងតរៀងទៅ ។

-ដើម្បីបង្កើតឡើងនូវសាមគ្គីភាព, ភាតរភាព, និងមិត្តភាពរវាងគ្នានឹងគ្នាឱ្យបានជាប់ជានិច្ចកាល ។

-ដើម្បីសិរីសួស្តីជ័យមង្គល សេចក្តីសុខចំរើនក្សេមក្សាន្តដល់ជីវិតនៅក្នុងឆ្នាំថ្មី ។

-ដីម្បីបំពេញនូវអប្បមាទធម៌ (ធម៌មិនធ្វេសប្រហែស) និងបុញ្ញកុសលឱ្យបានបរិបូណ៌នៅក្នុងសន្តានចិត្ត ។

-ដើម្បីសំដែងនូវកតញ្ញូកតវេទិតាធម៌ ចំពោះបុព្វការីជន មានមាតាបិតា ជីដូនជីតាជាដើម ដែលគាត់មានជីវិតរស់នៅក្តី ធ្វើមរណកាលទៅហើយក្តី បានដល់ការធ្វើតបស្នងសងគុណនិងឧទ្ទិសកុសលជូនទៅបុព្វការីជន និងញាតកិកាទាំង៧សន្តានផង។

-ដើម្បីគោរពនិងឧបត្ថម្ភព្រះពុទ្ធសាសនា ឱ្យបានរីកចំរើនរុងរឿងថ្កុំថ្កើងរៀងរហូតទៅអនាគតកាល ។

អាស្រ័យហេតុនេះ ក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម និងរៀបចំពិធីបុណ្យចូលឆ្នាំថ្មី **ឆ្នាំច អដ្ឋស័ក ព.ស. ២៥៥០ គ.ស. ២០០៦** ដូចមានកម្មវិធីខាងក្រោមនេះ ៖

✵ <u>ថ្ងៃសុក្រ ១រោច ខែចេត្រ ពស ២៥៥០ ត្រូវនិងថ្ងៃទី ១៤ ខែមេសា គស ២០០៦</u>

☸ វេលាម៉ោង ៦:៤៨ ព្រឹក : ពិធីនមស្សការ សូត្រមន្ត ទទួលទេវតាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** ។

☸ វេលាម៉ោង ៩:៣០ ព្រឹក : ពិធីនមស្សការ សមាទានសីល រាប់បាត្រ ដារបង្សុកូល វេរភត្តដល់ព្រះសង្ឃ។

☸ វេលាម៉ោង ៦:០០ ល្ងាច : គោរពទង់ព្រះពុទ្ធសាសនា, អធិដ្ឋានពូនភ្នំខ្សាច់ រំលឹកដល់ព្រះចូឡាមុនីចេតិយ នមស្សការ សុំសីល សូត្រមន្ត ធម្មវិសេសទេសនា ។

✵ <u>ថ្ងៃសៅរ៍ ២រោច ខែចេត្រ ពស ២៥៥០ ត្រូវនិងថ្ងៃទី ១៥ ខែមេសា គស ២០០៦</u>

☸ វេលាម៉ោង ៩:០០ ព្រឹក : ពិធីនមស្សការ សមាទានសីល សុន្ទរកថាបុណ្យចូលឆ្នាំថ្មី បិណ្ឌបាត ដារបង្សុកូល សំដែងធម្មីកថា វេរភត្តដល់ព្រះសង្ឃ ឧទ្ទិសគាថា។

☸ វេលាម៉ោង ១:០០–៣:០០ រសៀល កំសាន្តល្បែង: ខ្មែរប្រជាប្រិយ........

☸ វេលាម៉ោង ៣:០០ រសៀល ដល់ម៉ោង ១០:០០ យប់ សំដែងសិល្បៈ របាំបុរាណ តូរ្យតន្ត្រី **រុយក្បាលខៀវ,** ចំរៀងសម័យ, តាំងពិពណ៌, លក់ម្ហូបអាហារ, និងវត្ថុផ្សេងៗ ក្នុងបរិវេណនៃវត្តមុនីសុតារាម ។

✵ <u>ថ្ងៃអាទិត្យ ៣រោច ខែចេត្រ ពស ២៥៥០ ត្រូវនិងថ្ងៃទី ១៦ ខែមេសា គស ២០០៦</u>

☸ វេលាម៉ោង ៩:៣០ ព្រឹក : ពិធីនមស្សការ សមាទានសីល រាប់បាត្រ ដារបង្សុកូល វេរភត្តដល់ព្រះសង្ឃ។

☸ វេលាម៉ោង ១:០០ រសៀល ពិធីស្រង់ទឹកព្រះពុទ្ធរូប ជាកិច្ចឆ្លងបុណ្យចូលឆ្នាំថ្មី ។

ពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា
THE MINNESOTA CAMBODIAN BUDDHIST SOCIETY; INC.
A NON-PROFIT RELIGIOUS INCORPORATION
2925 220th Street East, Hampton, MN 55031 Tel: (651) 463-3101 Fax: (651) 460-4464
www.wattmunisota.org

# HAPPY NEW YEAR

Cambodian New Year is a Khmer traditional ceremony originated in the ancient time. The New Year is celebrated to achieve the following 6 goals:

1. To maintain or make existence of our beautiful tradition last for ever on this world.
2. To strengthen the solidarity, brotherhood, as well friendship, among our fellow Khmer nation.
3. To wish for good luck, happiness, and peace for ourselves.
4. To have our fellow Cambodian stay out of negligence and merit for ever step of life.
5. To gratefully pay back the favour of our ancestral fountainhead living or passed away parents and grand parents; meanwhile, May we dedicate the merit to our ancestors and relatives.
6. To respect and support for Buddhism which we believe is the best way for prosperous, glorious, and happiness of human being on this world forever.

To celebrate the year of the Dog, you, your family and friends are cordially invited to participate our annual celebration that the following events:

**<u>Friday, April 14, 2006</u>**

➦ 6:48 a.m.: Paying respect to the Triple Gem; Chanting the Paritta (Blessing); and Greeting the New Year Deity named **KEMIRA DEVI**.

➦ 9:30 a.m.: Paying respect to the Triple Gem; Taking the Five Precepts; putting alms into Almsbowls; Food Offering; and Lunch for Buddhist Monks.

➦ 6:00 p.m. Gathering and hoisting of the flag, Setting up sand mounts for Chulamuni Chetey, Paying homage to the Triple Gem, taking the Precepts, Blessing, and Sermon on the Dhamma.

**<u>Saturday, 15 April, 2006</u>**

➦ 9:00 a.m.: Paying respect to the Triple Gem; Taking the Five Precepts; putting alms into almsbowls, Food Offering; and Lunch for Buddhist Monks.

➦ 1:00p.m. - 3p.m.: Playing folk games

➦ 3:00p.m. - 10:00p.m. Traditional Dance; Concert with modern songs; Food/beverages are available for sale in Watt Munisotaram.

**<u>Sunday, 16 April, 2006</u>**

➦ 9:00 a.m.: Paying respect to the Triple Gem; Taking the Five Precepts; putting alms ceremony (Rabbat), Food Offering; and Lunch for Buddhist Monks.

➦ 1:00 p.m.: Sprinkling holy water on the Buddha statues.

Don’t miss this once a year celebration!